# **ដីកាបញ្ជាបណ្ដោះអាសន្ន  សំរាប់ការពារ  និងលិខិតជូនដំណឹងសវនាការ**(គ្រប់សំណុំរឿង)
# **TEMPORARY ORDER FOR PROTECTION AND NOTICE OF HEARING (All Cases)**

នេះជាដីកាបញ្ជា ការពារបណ្ដោះអាសន្នពិត ដែលចៅក្រមចុះហត្ថលេខា ។ ដីកាបញ្ជានេះ ត្រូវទុកនៅក្នុងសំណុំរឿងសំរាប់តុលាការ ។ អ្នកត្រូវយកសេចក្ដីចម្លងនៃ ដីកាបញ្ជានេះ ពីស្មៀនតុលាការ ដើម្បីបង្ហាញដល់ប៉ូលីស ។

ចូរបំពេញឈ្មោះ ជាបដ្ឋនាការជន,ហើយចុះខែ/ថ្ងៃ/ឆ្នាំកំណើតរបស់អ្នក ត្រង់កន្លែងដែលនិយាយថា"ខែ/ថ្ងៃ/ឆ្នាំកំណើត"។ ចូរបំពេញឈ្មោះនិងខែ/ថ្ងៃ/ឆ្នាំកំណើត របស់អ្នកចុងចោទ ។ បើអ្នកមិនដឹងខែ/ថ្ងៃ/ឆ្នាំកំណើតទេ,ចូរចុះអាយុនៃអ្នកចុងចោទ។

**បើមិនមានក្មេងក្រោមអាយុជាប់ទាក់ទងទេ,**ចូរគូសប្រអប់ថា "មិនមានក្មេងក្រោមអាយុជាប់ទាក់ទងឡើយ" ។

**បើមានទាក់ទងនឹងក្មេងក្រោមអាយុផង**,ចូរចុះឈ្មោះ,អាយុ,សាសន៍ ហើយនិងភេទ នៃក្មេងនិមួយៗ ដែលជាប់ទាក់ទងជាមួយនៅ ក្នុងសំណុំរឿងនេះ ។

[ ចៅក្រមនឹងបំពេញអ្វីដែលនៅសល់នៃក្រដាសពាក្យ] ។
[ ចូរគូសប្រអប់ដូចគ្នា ដែលអ្នកបានគូសនៅលើក្រដាសបដ្ឋនាលិខិត]។

[ពត៌មានតទៅនេះ មានទាក់ទងដល់ចំណុចទីបី និងទីបួន,មានតែ: ចំណុចទីបី,កំរិតហាមឃាត់ជនឆ្លើយតប មិនឲ្យទៅជាន់ដី ឬចូលទៅផ្ទះអ្នក,មានកន្លែងចំហរទុកឲ្យអ្នកសរសេរ អាសយដ្ឋានរស់នៅរបស់អ្នក ។ អ្នកមានសិទ្ធិរក្សាអាសយដ្ឋានទីលំនៅរបស់អ្នក ដោយអាថ៌កំបាំង(សម្ងាត់) ។ គេមិនតម្រូវឲ្យអ្នកចុះ អាសយដ្ឋានរស់នៅរបស់អ្នកឡើយ បើអ្នកមានកង្វល់អំពីសន្តិសុខ ឬអំពីការលួច យកអត្តសញ្ញាណប័ណ្ណរបស់អ្នក ។ ថ្វីបើយ៉ាងនេះក៏ដោយ,ការបង្ខំខាងផ្លូវច្បាប់នៃដីកាបញ្ជានេះ អាចមានភាព ស្រួលជាង បើអ្នកបានបញ្ចូលអាសយដ្ឋានរបស់អ្នកផង ។ បើអ្នកសំរេចថា បញ្ចូលអាសយដ្ឋានរបស់អ្នក,ចូរសរសេរ អាសយដ្ឋានឲ្យបានសព្វគ្រប់ ព្រមទាំងក្រុងផង ។

ចំណុចទីបួន,ផ្ដល់សិទ្ធិទាំងស្រុង សំរាប់ទីលំនៅ ដែលអ្នកហើយនិងជនឆ្លើយតបចែកគ្នានៅ,មានកន្លែងចំហរទុកឲ្យអ្នកសរសេរអាសយដ្ឋានទីលំនៅបានចែកគ្នា ។ អ្នកមានសិទ្ធិរក្សាអាសយដ្ឋានទីលំនៅរបស់អ្នកដោយ អាថ៌កំបាំង(សម្ងាត់) ។ គេមិនតម្រូវឲ្យអ្នកសរសេរចុះ អាសយដ្ឋានទីលំនៅរបស់អ្នកឡើយ បើអ្នកមានកង្វល់អំពីសន្តិសុខ ឬអំពីការលួចយកអត្តសញ្ញាណប័ណ្ណរបស់អ្នក ។ ថ្វីបើយ៉ាងនេះក៏ដោយ, អនុវត្តន៏តាមដីកា បញ្ជានេះ អាចមានភាពស្រួលជាង បើអ្នកបានបញ្ចូលអាសយដ្ឋានរបស់អ្នកផង ។ បើអ្នកសំរេចថា បញ្ចូល អាសយដ្ឋានរបស់អ្នក,ចូរសរសេរអាសយដ្ឋានឲ្យបានសព្វគ្រប់ ព្រមទាំងក្រុងផង] ។

**សវនាការលើកក្រោយ:** ប្រអប់ពត៌មាន នៅខាងក្រោមទំព័រទីពីរ ប្រាប់ជនឆ្លើយតប ឲ្យមកបង្ហាញខ្លួន តាម ខែ/ថ្ងៃ/ឆ្នាំ និងម៉ោងសវនាការលើកក្រោយ ។ អ្នកក៏ត្រូវអញ្ជើញមកសវនាការនេះដែរ ។ បើអ្នកមិនអញ្ជើញមកចូលរួមនៅក្នុងសវនាការ នេះទេ, តុលាការនឹងលុបបដ្ឋនាលិខិតរបស់អ្នកចោល ហើយគ្មានចេញដីកាបញ្ជាឲ្យការពារអ្នកឡើយ ។ បើមិនឆ្លើយតប និងមិនមកចូល រួមក្នុងសវនាការនេះទេ,តុលាការនៅតែប្រគល់ដីកាបញ្ជាការពារអ្នកដដែល,ដើម្បីឲ្យចុងចោទធ្វើតាមបដ្ឋនាលិខិត ហើយនិង ដីកា បញ្ជា ការពារបណ្ដោះអាសន្ន និងលិខិតសវនាការ បានត្រឹមត្រូវ ។ ចៅក្រមឬក្រឡាបញ្ជី នឹងសរសេរចុះ ខែ/ថ្ងៃ/ឆ្នាំ,ម៉ោង សំរាប់សវនាការ លើកក្រោយ ព្រមទាំងទីកន្លែង,នៅក្រោមចំណងជើងនៃទំព័រទីមួយ ។

## ជំនួយពីភ្នាក់ងារមានសមត្ថកិច្ច

ចូរគូសប្រអប់ឲ្យត្រឹមត្រូវ ហើយបំពេញត្រង់ទីភ្នាក់ងារមានសមត្ថកិច្ច ដែលអាចទៅដល់ **ទីកន្លែងអ្នករស់នៅ** ដើម្បីឲ្យគេអាចចុះ ដីកាបញ្ជានេះនៅក្នុងសម្ព័ន្ធកុំព្យូទ័រពេញរដ្ឋទាំងមូល ។

ចូរគូសប្រអប់ឲ្យត្រឹមត្រូវ ហើយបំពេញត្រង់ទីភ្នាក់ងារមានសមត្ថកិច្ច ដែលអាចទៅដល់ **ទីកន្លែងដែលចុងចោទរស់នៅ** ដើម្បី ឲ្យប៉ូលីសអាចប្រើដីកាបញ្ជានេះ ទៅលើចុងចោទបាន ។

បើអ្នកបានរៀបចំការនាំដំណឹងអំពីដីកាបញ្ជានេះ ដោយខ្លួនឯង,សូមគូសប្រអប់នោះ ។

បើអ្នកត្រូវការជំនួយពីប៉ូលិស ដើម្បីឲ្យបានចូលទៅក្នុងទីលំនៅរបស់អ្នក,ចូរគូសប្រអប់នោះ ។

បើអ្នកត្រូវការឲ្យគេជួយ ដើម្បីឲ្យបានវត្ថុជាកម្មសិទ្ធិផ្ទាល់ខ្លួនអ្នក,ចូរគូសប្រអប់នោះ ហើយនិងប្រអប់ ដែលបង្ហាញថា កម្មសិទ្ធិទាំងនោះ នៅក្នុងទីលំនៅរួមគ្នា,ទីលំនៅរបស់ចុងចោទ ឬនៅកន្លែងផ្សេងទៀត ។ (អ្នកនឹងត្រូវការធ្វើការទាក់ទងទីភ្នាក់ងារក្រសួងមានសមត្ថកិច្ចក្នុងតំបន់អ្នក ដើម្បីណាត់ពេលជួបនិងគេ នៅពេលនិងកន្លែងសំរាប់ជួប ដើម្បីឲ្យក្រសួងមានសមត្ថកិច្ចជួយអ្នក) ។

បើអ្នកត្រូវការជំនួយ ដើម្បីបានទទួលការគ្រប់គ្រងកូនរបស់អ្នក,ចូរគូសប្រអប់នោះ ។ (មានកម្រិតតាមផ្លូវច្បាប់ដែលក្រសួងមានសមត្ថកិច្ចអាចធ្វើបាន ។ ចូរទាក់ទងក្រសួងទីភ្នាក់ងារមានសមត្ថកិច្ចប្រចាំបន់អ្នក) ។

ចូរគូសប្រអប់ "ផ្សេងៗ" បើអ្នកត្រូវការជំនួយបន្ថែម ហើយរៀបរាប់អំពីប្រភេទនៃជំនួយនោះ ។

ប្រយោគចុងក្រោយបង្អស់,ខាងលើបន្ទាត់ខែ/ថ្ងៃ/ឆ្នាំ,និយាយប្រាប់ទាំងពីរ,គឺអ្នកហើយនិងជនឆ្លើយតប ឲ្យដឹងថា កិច្ចការពារមានចែងនៅក្នុងដីកាបញ្ជាបណ្តោះអាសន្ននេះ ប្រសិទ្ធិភាព បានដល់ត្រឹមពេលសវនាការលើកក្រោយនេះ ប៉ុណ្ណោះ ។

ចូរចុះហត្ថលេខាខាងក្រោមនៃក្រដាសពាក្យ ត្រង់កន្លែងនិយាយថា "បានបង្ហាញដោយ "និង "បដ្ឋទាជន " ។

តទៅនេះគឺជាតំណាងនៃដីកាបញ្ជាបណ្តោះអាសន្ន សំរាប់ការពារ ហើយនិងលិខិតជូនដំណឹងសវនាការ:

# តំណាង

**តុលាការវ៉ាស៊ីនតោន សំរាប់**

______ បដ្ឋនាជន ______ ខែ/ថ្ងៃ/ឆ្នាំកំណើត

vs.

______ ចុងចោទ ______ ខែ/ថ្ងៃ/ឆ្នាំកំណើត

លេខ:

**ដីកាបញ្ជាបណ្តោះអាសន្ន សំរាប់ការពារ ហើយនិងលិខិតជូនដំណឹងសវនាការ**

(TMORPRT) (គ្រប់សំណុំរឿង)

(តម្រូវឲ្យមានសកម្មភាពរបស់ស្មៀន)

**ខែ/ថ្ងៃ/ឆ្នាំ និងពេលម៉ោងសវនាការលើកក្រោយ:** ______

**នៅ:** ______

______

អត្តសញ្ញាណប័ណ្ណនៃក្មេងក្រោមអាយុ: ☐ មិនមានក្មេងក្រោមអាយុរួមទេ ។

| ឈ្មោះ<br>ខ្លួន,កណ្តាល,អក្សរដើម,ត្រកូល | អាយុ | សាសន៍ | ភេទ |
|---|---|---|---|
| | | | |

សំរាប់មូលហេតុសមរម្យ ដែលបានបង្ហាញ,តុលាការសំរេចថា មានភាពអាសន្ន ហើយគឺថា អាចត្រូវចេញដីកាបញ្ជាការពារបណ្តោះអាសន្ន ដោយមិនចាំបាច់ប្រាប់ជនឆ្លើយតបឲ្យដឹងទេ ដើម្បីចៀសវាងកុំឲ្យមានគ្រោះថ្នាក់ ។ **ដូច្នេះតុលាការបញ្ជាថា:**

| | |
|---|---|
| | 1. ចុងចោទត្រូវច្បាប់ហាមឃាត់ពីការធ្វើឲ្យបដ្ឋនាជន មានគ្រោះថ្នាក់,របួសខ្លួនប្រាណ,វាយតប់,រួមទាំងការរំលោភផ្នែកភេទ,ហើយនិងព្យាបាទ,ប្រើពាក្យអសុរោះ គំរាម,ឬឈ្លបចាប់ ☐ បដ្ឋនាជន ☐ ក្មេងក្រោមអាយុមានឈ្មោះត្រង់អត្ថបទលេខ៥ខាងលើ ☐ តែក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ ។ |
| | 2. ចុងចោទ មិនត្រូវមកក្បែរ ឬទាក់ទងតាមប្រការណាមួយ,ទោះជាផ្ទាល់បុគ្គល ឬតាមរយ:ជនដទៃ, តាមទូរស័ព្ទ,សំបុត្រ, ឬតាមមធ្យោបាយណាមួយ ទោះជាដោយចំពោះ ឬមិនចំពោះ,លើកលែងតែការផ្ញើ ឬការបំរើនៃទំរង់ការឯកសារតុលាការ តាមភាគីទីបី ឬទាក់ទងមេធាវី របស់ចុងចោទជាមួយ ☐ បដ្ឋនាការជន ☐ ក្មេងក្រោមអាយុមានឈ្មោះត្រង់អត្ថបទលេខ៥ ខាងលើ ☐ តែក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ ។ |

| | |
|---|---|
| | 3. ចុងចោទ មិនត្រូវដើរចូលទៅក្នុងបរិវេណដី ឬចូលទៅក្នុងទីលំនៅ □ បដ្ឋនាជន □ កន្លែងធ្វើការ □ សាលារៀន;□ មន្ទីរថែទាំ ឬសាលាលារៀន □ របស់ក្មេងមានឈ្មោះនៅតារាងខាងលើ □ តែក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ:<br>□ ផ្សេងៗ:<br>□ អាសយដ្ឋានបដ្ឋនាជន ត្រូវទុកជាអាថិកំបាំង ។ □ បដ្ឋានាជន បានបដិសេធភាពអាថិកំបាំងនៃអាសយដ្ឋាននេះ ដែលជា: |
| | 4. បដ្ឋនាជននឹងមានសិទ្ធិគ្រប់គ្រាន់ ទៅលើទីលំនៅ ហើយនិងទីលំនៅចែកគ្នា ។ ចុងចោទ **ត្រូវចេញ** ពីផ្ទះនោះជា បន្ទាន់ ។ ចុងចោទ អាចយកសំលៀកបំពាក់ជាកម្មសិទ្ធិ ហើយនិងសម្ភារៈរបស់ខ្លួន ចេញពីទីលំនៅ នៅពេលដែលក្រសួងមានសមត្ថកិច្ចកំពុងនៅទីនោះ ។□ អាសយដ្ឋាននេះ ត្រូវទុកជាអាថិកំបាំង □ បដ្ឋនាការជន បានបដិសេធភាពអាថិកំបាំងនៃអាសយដ្ឋាននេះ ដែលជា: |
| | 5. ចុងចោទបានត្រូវហាមឃាត់ មិនត្រូវមកនៅដោយចេតនា,ឬរស់នៅក្នុងរវាង ____________________ (ចម្ងាយ): □ ទីលំនៅរបស់បដ្ឋនាការជន □ កន្លែងធ្វើការ □ សាលារៀន □ កន្លែងមើលក្មេង ឬសាលារៀននៃ □ ក្មេងក្រោមអាយុមានឈ្មោះត្រង់អត្ថបទនៅតារាងខាងលើ □ តែក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ<br>□ ផ្សេងៗ: |
| | 6. បដ្ឋនាជន នឹងត្រូវបានរបស់ជាកម្មសិទ្ធិចាំបាច់ដែលមានរួមបញ្ចូល ដូចតទៅ: |
| | 7. បដ្ឋនាការជន មានសិទ្ធិប្រើរថយន្តដូចតទៅ:<br>ឆ្នាំ,ម៉ាក,ម៉ូដែល ______________________________ លេខឡាន: ____________ |
| | 8. **ផ្សេងៗ:** |
| ចូរបំពេញដូចតទៅ បើកិច្ចការពារនេះ ផ្តល់ឲ្យសំរាប់តែក្មេងក្រោមអាយុប៉ុណ្ណោះ: | |
| | 12. តុលាការបានប្រគល់សិទ្ធិ ដល់បដ្ឋនាជន ឲ្យថែទាំ,គ្រប់គ្រង,និងត្រួតត្រាបណ្តោះអាសន្នចំពោះ □ ក្មេងក្រោមអាយុមានឈ្មោះនៅ តារាងខាងលើ □ តែក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ: |
| | 13. តុលាការបានហាមឃាត់មិនឲ្យចុងចោទ ធ្វើការជ្រៀតជ្រែកអាណាព្យាបាលផ្លូវកាយ ឬផ្លូវច្បាប់ដល់បដ្ឋនាជន ចំពោះ □ ក្មេងក្រោមអាយុមានឈ្មោះនៅតារាងខាងលើ □ ក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ: |
| | 14. ច្បាប់ហាមមិនឲ្យចុងចោទយកចេញពីរដ្ឋនូវ □ ក្មេងក្រោមអាយុមានឈ្មោះនៅតារាងខាងលើ □ តែក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ: |

ចុងចោទ ត្រូវគេបង្គាប់ឲ្យមកបង្ហាញខ្លួន ហើយនិងបង្ហាញមូលហេតុថា ហេតុអ្វីបានជា ដីកាបញ្ជាបណ្តោះអាសន្ននេះ មិនអាចមានប្រសិទ្ធិភាពប្រើបានមួយឆ្នាំ ឬក៏លើសពីនោះ ហើយនិងមូលហេតុថា ហេតុអ្វីបានតុលាការ មិនចេញដីកាបញ្ជាដែលបដ្ឋនាជន បានស្នើ ឬក៏បញ្ចេញអ្វីផ្សេងទៀត,ដូចជាការត្រួតពិនិត្យនៅផ្ទះជាអេឡិចត្រូនិក,ការចេញតម្លៃផ្សេងៗ ហើយនិងការព្យាបាល ។ ការមិនបានមកបង្ហាញខ្លួននៅពេលសវនាការ អាចបណ្តាលឲ្យតុលាការផ្តល់ឲ្យមានការផ្លាស់ប្តូរសវនាការបែបនេះ ។ **ខែ/ថ្ងៃ/ឆ្នាំ និងពេលម៉ោង សវនាការលើកក្រោយ នឹងមានបង្ហាញនៅក្រោមចំណងជើងនៃទំព័រទីមួយ ។**

**ការព្រមានដល់ចុងចោទ:** ការបំពានលើកិច្ចសន្យានៃដីកាបញ្ជា ដែលមានលិខិតបញ្ជាក់ពីរយៈពេលពិត គឺជា ឧក្រិដ្ឋកម្ម នៅក្រោម Chapter 26.50 RCW ហើយគេនឹងចាប់ចង ជនប្រព្រឹត្តបំពាននេះ ។ ប្រសិនបើការបំពាននៃកិច្ចការពារ បានឆ្លងផុតពីខ្សែបន្ទាត់រដ្ឋ ឬហួសពីគណៈវិនិច្ឆ័យនៃកុលសម្ព័ន្ធ ឬចូលក្នុងរវាងព្រំដែនទឹក ហើយនិងគណៈវិនិច្ឆ័យនៃសហរដ្ឋអាមេរិក, ដែលរួមចូលទាំងដីរបស់កុលសម្ព័ន្ធ, ចុងចោទអាចត្រូវជាប់ពិរុទ្ធលើឧក្រិដ្ឋកម្ម នៅក្នុងតុលាការសហព័ន្ធ នៅក្រោមច្បាប់ 18 U.S.C. §§ 2261, 2261A, ឬ 2262 ។

ការបំពានលើដីកាបញ្ជានេះ គឺជាទោសបទមជ្ឈិមទាំងបំពាន លុះត្រាតែអនុវត្តនិងករណីណាមួយ ចំណោមករណីដូចតទៅនេះ: ការ វាយតប់ណាមួយ ដែលជាការបំពាន ទៅលើដីកាបញ្ជានេះ ហើយការវាយតប់នេះ មិនចាត់ចូលទៅក្នុងកំរិតទីមួយ ឬទីពីរ នៅ ក្រោមច្បាប់ RCW 9A.36.001 ឬ 9A.36.021 គឺជាឧក្រិដ្ឋកម្មថ្នាក់ C ។ ដំណើរការនៃការបំពាននៃដីកាបញ្ជានេះ ដែលជា ការធ្វេសប្រហែស ហើយធ្វើឲ្យមានគ្រោះថ្នាក់ដល់ស្លាប់ ឬមានរបួសរាងកាយយ៉ាងធ្ងន់ ដល់ជនណាមួយ គឺជាឧក្រិដ្ឋកម្មថ្នាក់ C ។ ម្យ៉ាងទៀត, ការបំពាននៃដីកាបញ្ជានេះ គឺជាឧក្រិដ្ឋកម្មថ្នាក់ C បើចុងចោទ មានទោសពីមុន យ៉ាងតិចបំផុតត្រឹមពីរដង ដោយការ បំពានលើច្បាប់ការពារ ដែលបានចេញទៅឲ្យនៅក្រោមច្បាប់ Title 10, 26 ឬ 74 RCW ។

បើតុលាការចេញដីកាបញ្ជាការពារ ជាចុងក្រោយ,ចុងចោទ មិនអាចមានកាំភ្លើង ឬគ្រាប់រំសេវឡើយ, ដរាបណា ដីកាចុងក្រោយ នៅ មានប្រសិទ្ធិភាពនៅឡើយ ។ 18 U.S.C. §§ 922(g)(8) ។ ការបំពានលើច្បាប់កាំភ្លើងនៃសហពន្ធ នាំឲ្យពិន័យទោសជាប់គុក អាច ដល់ទៅចំនួន១០ឆ្នាំ ហើយនិងត្រូវពិន័យជាប្រាក់ដល់ទៅ $250,000 ។ ចំពោះក្រសួងមានសមត្ថកិច្ច ហើយនិងបុគ្គលិកយោធា ដែលនឹងត្រូវលើកលែងបាន គឺនៅពេលដែលក្រសួង/រដ្ឋ បានចេញកាំភ្លើងនោះឲ្យកាន់ ។ 18 U.S.C. § 925(a)(1) ។ បើចុងចោទ មានទោស ដោយសារហឹង្សាគ្រួសារ, គេនឹងហាមមិនឲ្យចុងចោទនោះ មានកាំភ្លើងឬគ្រាប់រំសេវអស់មួយជីវិត 18 U.S.C. § 922(g)(9); RCW 9.41.040 ។

**អ្នកអាចត្រូវគេចាប់ចងបាន ទោះបីជា ជនណាម្នាក់ ឬជនដែលបានទទួលដីកាបញ្ជា បានប្រាប់ឬអនុញ្ញាត ឲ្យអ្នកបំពានលើដីកាបញ្ជាហាមឃាត់នេះក៏ដោយ** ។ អ្នកជាជនតែម្នាក់ឯងគត់ ដើម្បីទទួលភារៈកិច្ច ចៀសវាងទប់ ពីការបំពាន លើកិច្ចសន្យារបស់ដីកាបញ្ជានេះ ។ មានតែតុលាការទេ ដែលអាចដូរដីកាបញ្ជានេះ យោលទៅតាមពាក្យសុំជាលាយលក្ខណ៍អក្សរ ។

យោលទៅលើច្បាប់ 18 U.S.C. § 2265 ,តុលាការក្នុងរដ្ឋណាមួយ ចំណោមទាំង៥០រដ្ឋ, the District of Columbia, Puerto Rico, ដែនដីសហរដ្ឋ,និងដីកុលសម្ព័ន្ធ ក្នុងសហរដ្ឋ ត្រូវយល់ស្របតាមដីកាបញ្ជានេះទាំងអស់ ។

នេះជាបញ្ជាទៅថ្ងៃមុខថា ក្រឡាបញ្ជី ត្រូវបញ្ជូនសេចក្តីចម្លង នៃដីកាបញ្ជានេះ នៅក្នុងថ្ងៃ ឬមុនថ្ងៃធ្វើការវិនិច្ឆ័យលើកក្រោយឲ្យទៅ ______________________ ☐ ការិយាល័យប៉ូលិសខោនធី ☐ ក្រសួងប៉ូលិស **ដែលបដ្ឋទាជនរស់នៅ** ដែលគេត្រូវចុះនៅក្នុងកុំព្យូទ័រ-យោលទៅលើសម្ព័ន្ធបញ្ញាវ័ន្តឧក្រិដ្ឋកម្ម ដែលមានលទ្ធភាព នៅក្នុងរដ្ឋនេះ ដែលក្រសួងមានសមត្ថកិច្ចប្រើសំរាប់ដីកាពិសេស ។

☐ ក្រឡាបញ្ជី ត្រូវបញ្ជូនសេចក្តីចម្លង នៃដីកាបញ្ជានេះ នៅថ្ងៃ ឬមុនថ្ងៃធ្វើការវិនិច្ឆ័យលើកក្រោយឲ្យទៅ ______________________ ☐ ការិយាល័យប៉ូលិសខោនធី
☐ ក្រសួងប៉ូលិស **ដែលចុងចោទរស់នៅ** ដែលគេ នឹងផ្តល់ឲ្យចុងចោទ នូវសេចក្តីចម្លងនៃដីកាបញ្ជានេះ ហើយបំពេញនឹងបញ្ជូនភស្តុតាងតុលាការនេះ ឲ្យបានទាន់ពេល ។

☐ បដ្ឋទាជន បានរៀបចំការបំរើនៃបញ្ជានេះជាឯកជន ។

☐ ទីភ្នាក់ងារក្រសួងមានសមត្ថកិច្ច កន្លែងដែល ☐ បដ្ឋទាជន ☐ ចុងចោទរស់នៅ ត្រូវជួយបដ្ឋទាជន ឲ្យបានទទួលយក:
☐ ទីលំនៅរបស់ ☐ បដ្ឋទាជនវិញ ☐ កម្មសិទ្ធិផ្ទាល់ខ្លួន ដែលមាននៅ: ☐ ផ្ទះចែកគ្នា
☐ ផ្ទះរបស់ចុងចោទ ☐ ផ្សេងៗ: ______________________.
☐ ការគ្រប់គ្រងក្មេងក្រោមអាយុដែលមានឈ្មោះខាងលើ រួមបញ្ចូលទាំងអាណាព្យាបាលខ្លួនប្រាណ សំរាប់យកទៅឲ្យបដ្ឋទាជន (បើមានលទ្ធភាព) ។
☐ ផ្សេងៗ: ______________________.

**ដីកាបញ្ជាបណ្តោះអាសន្ន សំរាប់ការពារនេះ មានប្រសិទ្ធិភាព រហូតដល់ពេលសវនាការលើកក្រោយ ដែលមានបង្ហាញនៅ ក្រោមចំណងជើងនៃទំព័រលេខមួយ ។**

បានចុះនៅ ______________________ ម៉ោង __________ ព្រឹក/រសៀល ។

______________________
ចៅក្រម/គណៈកម្មាធិការតុលាការ

បានបង្ហាញដោយ:

______________________
បដ្ឋទាជន